**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ ក្រុមអ្នកជំនាញ អ.ស.ប មានកង្វល់ពីការចាប់ខ្លួនជុំវិញវិធីបុណ្យរំឭកខួបមរណភាព លោក កែម ឡី

ទីក្រុងហ្សឺណែវ (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩) ក្រុមអ្នកជំនាញសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅថ្ងៃនេះ បានអំពាវនាវឲ្យអាជ្ញាធរកម្ពុជាដោះលែង និងទម្លាក់ចោលបទចោទទាំងឡាយលើបុរសពីររូប ដែលត្រូវបាន ចាប់ខ្លួនពាក់ព័ន្ធនឹងសកម្មភាពរំឭកខួបបីឆ្នាំនៃការធ្វើឃាតលើអ្នកវិភាគនយោបាយ និងសកម្មជនសង្គម លោក កែម ឡី។

លោក គង់ រ៉ៃយ៉ា ត្រូវបានចាប់ខ្លួន នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងការបង្ហោះលើទំព័រហ្វេសប៊ុក លក់អាវយឺតដែលមានរូបលោក កែម ឡី និងផ្តល់ព័ត៌មានលម្អិតអំពីសេវាតាក់ស៊ីធ្វើដំណើរទៅកាន់កន្លែង ប្រារព្ធពិធីរំឭកខួបនៅថ្ងៃបន្ទាប់។ លោក សួង នាគព័ន្ធ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ខណៈពេលដែលលោកកំពុងព្យាយាមចូលរួមក្នុងពិធីបុណ្យរំឭកខួបលោក កែម ឡី។ បុរសទាំងពីររូបនោះ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។

ក្រុមអ្នកជំនាញ អ.ស.ប បានមានប្រសាសន៍ថា "យើងមានកង្វល់អំពីការចាប់ខ្លួន ការឃុំខ្លួន និងការចោទ ប្រកាន់ពីបទព្រហ្មទណ្ឌទៅលើលោក គង់ រ៉ៃយ៉ា និងលោក សួង នាគព័ន្ធ។" "យោងតាមព័ត៌មានដែលយើង ទទួលបាន លោកគង់ រ៉ៃយ៉ា និងលោក សួង នាគព័ន្ធ បានចូលរួមក្នុងការអនុវត្តស្របច្បាប់នូវសេរីភាពក្នុងការ សម្តែងមតិរបស់ពួកគេ ហើយលោក សួង នាគព័ន្ធ ហៀបនឹងបានចូលរួមនៅក្នុងពិធីបុណ្យរំឭកខួបដោយ សន្តិវិធី។ ជាថ្មីម្តងទៀត យើងមានកង្វល់ថា អាជ្ញាធរកំពុងកំណត់គោលដៅលើសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី"។

ក្រុមអ្នករាយការណ៍ពិសេស បានសម្តែងកង្វល់កន្លងមក អំពីការបង្ក្រាបដែលនៅតែកើតមានទៅលើសង្គមស៊ីវិល និងទៅលើការអនុវត្តសេរីភាពជាមូលដ្ឋាន។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "យើងសូមអំពាវនាវជាថ្មីម្តងទៀតដល់រដ្ឋាភិបាល ឲ្យបង្វែរនិន្នាការ ដែលធ្លាក់ចុះនាពេលបច្ចុប្បន្ននៃការអនុវត្តនូវសេរីភាពជាមូលដ្ឋាន។" "ការពិភាក្សាដោយបើកចំហលើប្រធាន បទផ្សេងៗ សូម្បីតែនៅពេលដោះស្រាយបញ្ហារសើប ឬបញ្ហាសំខាន់ៗក៏ដោយ មិនគ្រាន់តែជាការបញ្ចប់បញ្ហា ដែលកើតមានប៉ុណ្ណោះទេ វាថែមទាំងជាមធ្យោបាយមួយដើម្បីលើកកម្ពស់មតិយោបល់ គំនិតច្នៃប្រឌិត និង ការពិភាក្សាដេញដោលដែលចាំបាច់ដើម្បីជំរុញកម្ពុជាឲ្យឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិ ភាពយូរអង្វែង"។

ក្រុមអ្នករាយការណ៍ពិសេស ក៏បានសម្តែងកង្វល់ផងដែរថា រយៈពេលបីឆ្នាំកន្លងមកនេះ ហាក់មិនមានការ ស៊ើបអង្កេតដោយឯករាជ្យ និងមិនលំអៀងជាក់ស្តែងណាមួយ ទៅលើករណីឃាតកម្មលើលោក កែម ឡី នោះទេ។ បន្ទាប់ពីសវនាការកន្លះថ្ងៃ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ សាលាដំបូងរាជធានីភ្នំពេញ បានរកឃើញបុគ្គល

មួយរូបថាមានពិរុទ្ធ ពីបទឃាតកម្ម ហើយបានផ្តន្ទាទោសបុគ្គលរូបនោះដាក់ពន្ធនាគារអស់មួយជីវិត។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ តុលាការកំពូលបានតំកល់ទោសដាក់ពន្ធនាគារអស់មួយជីវិតនោះ។ ការស៊ើបអង្កេតដែលកំពុងបន្តស្វែងរកអត្តសញ្ញាណជនដទៃទៀតដែលជាប់ពាក់ព័ន្ធនឹងការធ្វើឃាតលើលោក កែម ឡី ទំនងជាត្រូវជាប់គាំងហើយ ដោយគ្មាននរណាម្នាក់ត្រូវបានកោះហៅពាក់ព័ន្ធនឹងការស៊ើបអង្កេតនេះឡើយ។

ក្រុមអ្នករាយការណ៍ពិសេស បានមានប្រសាសន៍ថា "យើងមានកង្វល់អំពីការខកខានជាក់ស្តែងមិនបានធ្វើការស៊ើបអង្កេតឲ្យបានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ឲ្យច្បាស់អំពីករណីឃាតកម្មលើលោក កែម ឡី"។ ក្រុមអ្នករាយការណ៍ពិសេសក៏បានមានប្រសាសន៍ផងដែរថា "យើងសូមអំពាវនាវឲ្យរដ្ឋាភិបាលបង្កើតស្ថាប័នឯករាជ្យមួយ ដើម្បីធ្វើការស៊ើបអង្កេតប្រកបដោយតម្លាភាព និងមិនលំអៀង ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន" ដោយអំពាវនាវឲ្យមានការជួយឧបត្ថម្ភគាំទ្រពីអន្តរជាតិក្នុងដំណើរការនេះ។

នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងសំឡេងឯករាជ្យដទៃទៀត ដូចជាអ្នកយកព័ត៌មាន លោក អ៊ួន ឈិន និង លោក យាង សុទ្ធារិន ក្រុមអ្នកជំនាញបានអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជា ចាត់វិធានការជាបន្ទាន់ និងប្រកបដោយអត្ថន័យ ដើម្បីការពារសុវត្ថិភាពអ្នកសារព័ត៌មាន ដែលត្រូវបានវាយប្រហារចំពោះការអនុវត្តសិទ្ធិសេរីភាពសម្តែងមតិរបស់ពួកគេ។

ក្រុមអ្នកជំនាញ អ.ស.ប បានទំនាក់ទំនងប្រាប់ពីកង្វល់របស់ពួកគាត់ទៅរដ្ឋាភិបាលរួចហើយ។

ចប់

*(*) **ក្រុមអ្នកជំនាញ៖ សាស្ត្រាចារ្យ រ៉ូណា ស្មីត** <u>អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា</u> លោក Clément Nyaletsossi Voulé <u>អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម</u> លោក **ដេវីដ ឃេយ៍** (David Kaye) <u>អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពនៃគំនិត និងសម្តែងមតិ</u> លោកស្រី Agnes Callamard <u>អ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ ឬការសម្លាប់ដោយបំពាន</u> និង **លោក មីសែល ហ្វ័ស្ត៍** (Mr. Michel Forst) <u>អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស</u>។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជា<u>នីតិវិធីពិសេស</u>របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញ ឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគាត់បម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា និងទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស៖*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស៖ កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖ លោកស្រី អ៊ីស្ទើរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩១ ០៨ ឬ តាមរយៈអ៊ីមែល elam@ohchr.org) លោក ម៉ាស័មូដ ហ្គារហ្គា (Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ ឬ អ៊ីមែល mgarga@ohchr.org) `*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក ហ្សេរ៉ឺមី ឡូរង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈ ទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)*